**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកណ្ដាល**

# ជំនួយស្មារតី

## ឯកឧត្តម ម៉ៅ ភិរុណ ប្រធានក្រុមប្រឹក្សាខេត្តកណ្ដាល

## ក្នុងសន្និសីទសារព័ត៌មាន ស្ដីពី " វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត "

## នៅទីស្ដីការគណៈរដ្ឋមន្ត្រី ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១

ជាបឋម ខ្ញុំព្រះករុណា-ខ្ញុំបាទ៖

- សូមក្រាបថ្វាយបង្គំ **សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្ដេចព្រះសង្ឃរាជ សម្ដេចព្រះរាជាគណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ** ជាទីគោរពសក្ការៈ !
- សូមគោរព និងជម្រាបសួរ **បងប្អូនជនរួមជាតិ ប្រជាពលរដ្ឋទូទាំងប្រទេស**
- សូមគោរព **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !
- សូមគោរព **សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរព **ឯកឧត្តម ផៃ ស៊ីផាន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល** ជាទីគោរព!
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មាន ដែលមានវត្តមាននៅក្នុងឱកាសនេះ ជាទីគោរពរាប់អាន!

ថ្ងៃនេះ តាងនាមរដ្ឋបាលខេត្តកណ្ដាល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្ដែងនូវសេចក្ដីសោមនស្សរីករាយដែលត្រូវបានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលអញ្ជើញឱ្យចូលរួមជាវាគ្មិនកិត្តិយសដើម្បីធ្វើបទបង្ហាញស្ដីពី " **វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត** " នាពេលនេះ ។ សមាសភាពគណៈប្រតិភូខេត្តកណ្ដាល ដែលអញ្ជើញចូលរួមក្នុងអង្គពិធីនេះរួមមាន សមាជិកក្រុមប្រឹក្សា អភិបាលរងខេត្ត នាយករដ្ឋបាលសាលាខេត្ត ប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត ប្រធានអង្គភាពច្រកចេញចូលតែមួយខេត្ត នាយិកាទីចាត់ការហិរញ្ញវត្ថុ នាយកទីចាត់ការផែនការ និងវិនិយោគ ប្រធានមន្ទីរព័ត៌មានខេត្ត ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត ប្រធានក្រុមប្រឹក្សា អភិបាលស្រុកកោះធំ មេឃុំសំពៅពូន ស្រុកកោះធំ មន្ត្រីជំនួយការ និងក្រុមព័ត៌មានខេត្ត ។

អនុញ្ញាតឱ្យខ្ញុំព្រះករុណា-ខ្ញុំបាទ សូមគោរពរាយការណ៍ជូន សម្ដេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អំពីស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សក្ដានុពល សមិទ្ធផលនៃការអភិវឌ្ឍន៍ ស្ថានភាពសេដ្ឋកិច្ច ការគ្រប់គ្រង ដឹកនាំ និងវឌ្ឍនភាពការងាររបស់ក្រុមប្រឹក្សាខេត្តកណ្ដាលសម្រេចបានក្នុងរយៈពេល២ឆ្នាំកន្លងមក ក្នុងអាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត ដូចតទៅ៖

ផ្អែកលើមូលដ្ឋានគ្រឹះដ៏រឹងមាំនៃសុខសន្តិភាព និងស្ថេរភាពនយោបាយ តាមរយៈការអនុវត្តគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាល និងនយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាប្រមុខដឹកនាំដ៏ឆ្នើមប្រកបដោយគតិបណ្ឌិត បាននាំនាវាកម្ពុជាឆ្ពោះទៅរកភាពចុំច្រើន និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម តាមរយៈការដាក់ចេញនូវ គោលនយោបាយ កម្មវិធីជាតិកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីពង្រឹងប្រព័ន្ធអភិបាលកិច្ចទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលដៅលើកកម្ពស់ការផ្តល់សេវា សាធារណៈ ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍនៅមូលដ្ឋាន ។

ដើម្បីឆ្លើយតបនឹងគោលដៅនេះ រដ្ឋបាលខេត្តកណ្តាល បានដាក់ចេញផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តនានា សំដៅជានាប្រសិទ្ធភាពនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។ ជាក់ស្តែង រដ្ឋបាលខេត្តកណ្តាលបានសម្រេចសមិទ្ធផលសំខាន់ៗជាច្រើន ក្នុងក្របខណ្ឌនៃការអនុវត្ត កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចនៅមូលដ្ឋាន និងបង្កើនចំណូលជូនប្រជាពលរដ្ឋឱ្យមានជីវភាពកាន់តែប្រសើរឡើង ដែលខ្ញុំសូមលើកឡើងអំពីសក្តានុពល និងសមិទ្ធផលធំៗសំខាន់ៗមួយចំនួនសម្រាប់រដ្ឋបាលខេត្តកណ្តាល រួមមាន៖

**១.អំពីស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ និងសេដ្ឋកិច្ច៖**

- ខេត្តកណ្តាល ស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា មានព្រំប្រទល់ខាងជើងជាប់នឹងខេត្តកំពង់ចាម-កំពង់ឆ្នាំង ខាងកើតជាប់នឹងខេត្តព្រៃវែង ខាងលិចជាប់នឹងខេត្តកំពង់ស្ពឺ-តាកែវ និងខាងត្បូងជាប់នឹងខេត្តតាកែវ និងខេត្តអានយ៉ាងនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
- មានផ្ទៃដី សរុប ៣ ២១១,៧៦ គ.ម២ (**យោង.របក.មន្ទីរ ដ.ន.ស.ស លេខ ២៩១ ដនសស.កណ ចុះថ្ងៃទី០៥.២.២១ផ្ទៃដីសល់ក្រោយកែសម្រួលព្រំប្រទល់ជាមួយរាជធានីភ្នំពេញ ៣ ២៥១,៥០គ.ម²** )
- មាន ១ក្រុង និង១០ស្រុក គ្របដណ្តប់លើ ១១៧ឃុំ និង ១០សង្កាត់ និងមានភូមិសរុប ១ ០១០ភូមិ។
- ប្រជាជនសរុប ១ ២៩១ ៥៨១នាក់ ដង់ស៊ីតេប្រជាជន ៤០២នាក់/១គ.ម២ (ផ្អែកតាមលទ្ធផលជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩)។
- ប្រជាពលរដ្ឋប្រកបមុខរបរសំខាន់ៗមានដូចជា កសិកម្ម ៥០,៥% សិប្បកម្ម ១,២% និងសេវាកម្ម ៤៨,៣% បានធ្វើឱ្យសេដ្ឋកិច្ចខេត្តមានការកើនឡើង
- ឆ្នាំ២០១៩ ខេត្តមានចំណូលក្នុងស្រុកសរុប(GDP)ប្រមាណ ១០ ៣៨៨ ៧៩៥ ៥០០ ០០០រៀល (ដប់ពាន់បីរយប៉ែតសិបប្រាបីប៊ីលាន ប្រាំពីររយកៅសិបប្រាំលាន ប្រាំរយពាន់រៀលគត់)
- ចំណូលសម្រាប់មនុស្សម្នាក់ ចំនួន ១ ៩៩៧ដុល្លារ បើប្រៀបធៀបនឹងឆ្នាំ២០១៨ មានចំនួន ១ ៨៦០ ដុល្លារ កើនឡើង ១៣៧ដុល្លារ
- អត្រាភាពក្រីក្រថយចុះពី ៥,៣៣% (ឆ្នាំ២០១៨) មកត្រឹម ៤,៥៧% (ឆ្នាំ២០១៩) ស្របតាមគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលឱ្យស្ថិតនៅ ក្នុងអត្រាទាបជាង១០%។
- បានអនុវត្តកម្មវិធីឧបត្ថម្ភជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដោយមានគ្រួសារមកផ្ទៀងផ្ទាត់ឈ្មោះ ៣៤ ៨៩០គ្រួសារ និងបានបើកសាច់ប្រាក់សរុប ៤៤ ៧៣៨ ៥០០ ០០០រៀល (៤៤ប៊ីលាន ៧៣៨លាន ៥០០ពាន់រៀល)

- បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដែលជាលទ្ធផលមានស្ត្រីសរុប ២ ៩៩៣នាក់ និងកុមារ ១ ៩៤៨នាក់ ស្មើនឹងថវិកាសរុប ១ ២៩៣ ១៦០ ០០០រៀល គត់ (មួយប៊ីលាន ពីររយកៅសិបបីលាន មួយរយហុកសិនពាន់រៀល)។
- កំណើនសេដ្ឋកិច្ចមានកម្រិតខ្ពស់(ឆ្នាំ២០១៩)៦,១% ទទួលបានវិស័យអាទិភាពចំនួនបី គឺ វិស័យកសិកម្ម ៣៧,១ %វិស័យឧស្សាហកម្ម ៣៦,៣ %និងវិស័យសេវាកម្ម ២៦,៧%។

**ក.<u>វិស័យកសិកម្ម៖</u>**

- ខេត្តកណ្តាល បានជំរុញឱ្យវិស័យកសិកម្ម ជាវិស័យស្នូលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចខេត្តច្រើនជាងគេ គឺ ៣៧,១%។
- ផ្ទៃដីកសិកម្មសរុបមាន ១៤១ ៩៩៦ហិកតា (ស្មើនឹង ៤៣,៦៧% នៃផ្ទៃដីខេត្ត) ក្នុងនោះ ផ្ទៃដីបង្កបង្កើនផលស្រូវ ១០២ ៥៧៨ហិកតា (៧២,២៤%) ផ្ទៃដីដំណាំកសិឧស្សាហកម្ម និងដំណាំរួមផ្សំ ៣៣ ៤៥៧ហិកតា(២៣,៥៦%) និងផ្ទៃដីដំណាំអនុផល ៥ ៩៦១ហិកតា(៤,២%)។
- ឆ្នាំ២០២០-២០២១៖
  - ✓ **ស្រូវវស្សា** ផែនការគ្រោង ៣០ ១០០ហិកតា អនុវត្តបាន ៣១ ០៣១ហិកតា ស្មើនឹង ១០៣,០៩% នៃ ផែនការ តិចជាងឆ្នាំ២០១៩ ចំនួន ៣ ៨៥៩ហិកតា (ដោយសារវងផលប៉ះពាល់ដោយជំនន់ទឹកភ្លៀង ៣ ៤៧២ហិកតា ខូចខាតទាំងស្រុង ១ ៤៦៤ហិកតា ស្តារឡើងវិញបាន ៥៤០ហិកតា)
  - ✓ **ផលស្រូវវស្សា** ៣០ ៣៩៥ហិកតា (បញ្ចប់ត្រឹមថ្ងៃទី១១ ខែមករា ឆ្នាំ២០២១) បរិមាណផល ១០២ ៦០១តោន ទិន្នផល ៣,៣៧៦ តោន/ហិកតា។
  - ✓ **ផលស្រូវប្រាំង** ផែនការ ៥៥ ៤០០ហិកតា អនុវត្តបាន ៥៥ ០៤៧ ហិកតា ស្មើនឹង ៩៩,៣៦ % នៃផែនការ (បញ្ចប់ត្រឹមថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១) តិចជាងឆ្នាំមុន ១ ៦១១ហិកតា។
  - ✓ **តុល្យភាពស្បៀងសល់ពីការផ្គត់ផ្គង់** គឺ ៣១ ៤០៥តោន(គិតជាស្រូវ) ស្មើនឹង ២០ ០៩៩តោន (គិតជាអង្ករ)។
  - ✓ **ដំណាំបន្លែ** ទទួលបរិមាណ ៧០ ១៧៤តោន/១ឆ្នាំ (អនុវត្តសរុប ៨ ៦១៦ ហ.ត) កើន ៣៤ ១៩១ តោន/១ឆ្នាំ ស្មើនឹង ៤៨,៧២ %បើធៀបនឹង ឆ្នាំ២០១៩ មាន ៣៥ ៩៨៣ តោន/១ឆ្នាំ (អនុវត្តសរុប ៤ ៣៨៩ ហ.ត)។
  - ✓ **ដំណាំរួមផ្សំ** ទទួលបរិមាណផល ១៦១ ៣៤៧តោន/ឆ្នាំ លើផ្ទៃដីដាំដុះ ២៧ ៦៨៦ ហ.ត។

**ខ.<u>វិស័យឧស្សាហកម្ម៖</u>**

- គិតមកដល់ឆ្នាំ២០២០ ខេត្តកណ្តាលមាន រោងចក្រសហគ្រាស សរុប ៤៥១ វិស័យផលិតសម្លៀកបំពាក់ និងដេរស្បែកជើង សរុបចំនួន ១៤៤ វិស័យធនាគារនិងហិរញ្ញវត្ថុ ចំនួន ១៣៦ វិស័យសិប្បកម្មផលិតផដ្ឋ ៧៣ ដែលបានផ្តល់ការងារជូនកម្មករសរុបចំនួន ១៣១ ១១៣នាក់ ស្រី ១១១ ៩១៤នាក់។
- វិស័យផលិតសម្លៀកបំពាក់ និងដេរស្បែកជើង សរុបចំនួន ១៤៤ អាចស្រូបយកប្រាក់ចំណូលក្នុងមួយខែ ៣១ ៩០៩ ៨៩០ដុល្លា។ សរុបជារួមក្នុងមួយឆ្នាំខេត្តកណ្តាលអាចស្រូបចំណូល ៣៨២ ៩១៨ ៦៨០ ដុល្លា។
- **វិស័យសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម** គិតត្រឹមឆ្នាំ២០២០ សរុបចំនួន ១ ៤០២មូលដ្ឋាន កើន ១៣មូលដ្ឋាន ស្មើនឹង ០,៩៤% បើធៀបនឹងឆ្នាំ២០១៩ ដែលមាន ១ ៣៨៩មូលដ្ឋាន។

- គិតត្រឹមថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១នេះ រោងចក្រ សហគ្រាស ចំនួន ៧៨ បានស្នើសុំព្យួរកិច្ចសន្យាការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងមានកម្មករសុំព្យួរ ចំនួន ៦៤ ៩៤២នាក់ ស្រី៥៣ ៦១៥នាក់ (ស្មើនឹង ៤៩,៥៣ %នៃចំនួនកម្មករសរុប) ដោយសារឥទ្ធិពលរីករាលដាលនៃជំងឺកូវីដ១៩។

**គ.<u>វិស័យសេវាកម្ម និងទេសចរណ៍៖</u>**

- ទេសចរណ៍នៅខេត្តកណ្តាល ជាទេសចរណ៍" ***វប្បធម៌ប្រវត្តិសាស្ត្រ និងធម្មជាតិ*** "បានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចខេត្ត ស្មើនឹង ២៦,៧ %នៃចំណូលថវិកាខេត្ត និងបានផ្តល់ការងារមួយផ្នែកជំជូនប្រជាពលរដ្ឋ។
- តំបន់ទេសចរណ៍សំខាន់ៗ រួមមាន ភ្នំព្រះរាជទ្រព្យ ភ្នំប្រសិទ្ធ កៀនស្វាយក្រៅ ស្ពានភ្នំ ស្ពាយលែន ចំការស្នេហ៍ អ្នកតាចិន និងគោលដៅទេសចរណ៍មួយចំនួនទៀត
- ផ្នែកសេវាកម្ម ខេត្តមានសណ្ឋាគារ ០២កន្លែង ផ្ទះសំណាក់ ៧៦កន្លែង មណ្ឌលកម្សាន្តមនុស្សពេញវ័យ ៦៤កន្លែង ភោជនីយដ្ឋាន ៤៧កន្លែង និងទីតាំងអាជីវកម្មផ្សេងជាច្រើនទៀត
- បានរៀបចំអភិវឌ្ឍទីក្រុងតាខ្មៅ និងបានទទួលពានរង្វាន់ទីក្រុងទេសចរណ៍ស្អាតអាស៊ានលើកទី២ សុពលភាពឆ្នាំ២០២០-២០២២ នៅរាជធានីប៉ង់ដារសិរីបេហ្គាវ៉ាន់ ប្រទេសព្រុយណេដារ៉ូសាឡឹម កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ និងពិធីដង្ហែក្បួនអបអរសាទរថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ ។
- ក្នុងឆ្នាំ២០២០ រដ្ឋបាលខេត្តបានយកចិត្តទុកដាក់ជំរុញវិស័យទេសចរណ៍ ដោយទទួលបានការវិនិយោគក្នុងវិស័យនេះនៅទីតាំងថ្មីៗដូចជា ព្រីនម៉ាណ័រ7 NG ភូមិផ្កាត្រកួនជាដើម
- ឆ្នាំ២០២០នេះ វិស័យទេសចរណ៍បានរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ១៩ ធ្វើឱ្យភ្ញៀវទេសចរណ៍ធ្លាក់ចុះ ប្រៀបធៀបនឹងឆ្នាំ២០១៩ មាន១២ ៣១១នាក់ គឺមានអត្រាថយចុះ ៤៩.៣៤%។

**ឃ.<u>ការងាររ៉ែ ថាមពល អគ្គិសនី និងទឹកស្អាត៖</u>**

- ខេត្តមានប្រតិបត្តិករផ្គត់ផ្គង់ និងចែកចាយអគ្គិសនី(រដ្ឋ និងឯកជន)ចំនួន ៦៤ ដែលបានផ្គត់ផ្គង់អគ្គិសនីដល់ភូមិទូទាំងខេត្ត ១០១០ភូមិ លើ ២២១ ០៨៦ខ្នងផ្ទះ ស្មើនឹង១០០ %។
- នៅឆ្នាំ២០១៩ តម្លៃអគ្គិសនីទូទាំងខេត្ត ៧៤០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង ថ្លៃអនុគ្រោះផ្សេងៗទៀត សម្រាប់អ្នកប្រើក្រោម ១០គីឡូវ៉ាត់ម៉ោង ថ្លៃ ៣៨០រៀល និង៤៨០រៀល សម្រាប់អ្នកប្រើក្រោម៥០ គីឡូវ៉ាត់ម៉ោង។
- បានដោះស្រាយសំណងផលប៉ះពាល់ជាមួយប្រជាពលរដ្ឋ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្ត ចំនួន៦ស្រុក ចំនួន ២៥៩បង្គោល
- បានសម្របសម្រួលដោះស្រាយក្នុងការសាងសង់រោងចក្រអគ្គិសនី ៤០០មេហ្គាវ៉ាត់ នៅឃុំកោះរះ ស្រុកល្វាឯម។
- ផលិតកម្ម អាជីវកម្មទឹកស្អាត សរុបចំនួន ៥០មូលដ្ឋាន ក្នុងនោះ ៤៩មូលដ្ឋានជារបស់ឯកជន និង ០១មូលដ្ឋានជារបស់រដ្ឋាករទឹកស្វយ័តភ្នំពេញ។
- បណ្តាញទឹកស្អាតដែលបានដាក់រួចរាល់ ៨៤៧ភូមិ រួមមាន ១៣៦ ៧៩៥ខ្នងផ្ទះ ស្មើនឹង ៦១,៨៧ % (រដ្ឋាករទឹក ១៨ ៤៥៧ខ្នងផ្ទះ និងឯកជន ១១៨ ៣៣៧ខ្នងផ្ទះ) ។
- បានសម្របសម្រួលជាមួយអាជីវករ និងរដ្ឋាករទឹកបានតបណ្តាញស្អាត ២២៨ទីតាំង និង ៣២៣០ បន្ទប់ដល់បន្ទប់ជួលកម្មករ និងនិស្សិត។
- មានអាជីវកម្មខ្សាច់ទន្លេ ១៧មូលដ្ឋាន, អាជីវកម្មខ្សាច់បក ១៩មូលដ្ឋាន, អាជីវកម្មថ្ម ១មូលដ្ឋាន, អាជីវកម្មជីកដី ៧៧មូលដ្ឋាន និងអាជីវកម្មដេប៉ូខ្សាច់ ៧៣មូលដ្ឋាន ។

**២.វឌ្ឍនភាពការងាររបស់ក្រុមប្រឹក្សាខេត្ត៖**

- អាណត្តិទី៣នេះ ខេត្តមានមន្ត្រីរាជការក្របខណ្ឌ សរុប ១ ០៦៥នាក់ ក្នុងនោះ រដ្ឋបាលខេត្ត ១៦២ នាក់) ស្រី ៥៥នាក់ (រដ្ឋបាលក្រុង ស្រុក ៩០៣នាក់) ស្រី ២៣០នាក់(។ ក្រុមប្រឹក្សាខេត្តអាណត្តិទី

៣ មាន ២៧នាក់) ស្រី ៦នាក់ (គណៈអភិបាលខេត្ត ៧នាក់) ស្រី ១នាក់ (និងក្រុមប្រឹក្សាក្រុង ស្រុក ២២១នាក់ គណៈអភិបាលក្រុង ស្រុក ៦៥នាក់ ក្រុមប្រឹក្សាឃុំ សង្កាត់ ៩១៥នាក់) ស្រី១៨២ នាក់ មេឃុំជាស្ត្រី ១៦នាក់(។

- បានប្រជុំសាមញ្ញទៀងទាត់ស្របតាមប្រតិទិនកំណត់ ជានាបានខ្លឹមសារ របៀបវារៈ ស្របតាម ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងបទបញ្ជាផ្ទៃក្នុង។
- បានរៀបចំកិច្ចប្រជុំវិសាមញ្ញ ដើម្បីពិនិត្យ និងដោះស្រាយបញ្ហាប្រឈមចាំបាច់ ស្របតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តដែលតម្រូវ ។
- បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ទៀងទាត់នៅក្នុងអំឡុងត្រីមាសទី៤ នៃឆ្នាំនីមួយៗ ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងបានប្រមូលយកបញ្ហា ទុក្ខកង្វល់ សំណើ សំណូមពររបស់ មូលដ្ឋានមកពិនិត្យ និងបានចាត់អាទិភាព និងធ្វើការដោះស្រាយតាមសមត្ថកិច្ច។
- បានរៀបចំកិច្ចប្រជុំវាយតម្លៃក្នុងការតែងតាំង ផ្លាស់ប្តូរ មុខតំណែងមន្ត្រី ប្រកបដោយសមត្ថភាព និង គុណវុឌ្ឍិគ្រប់គ្រាន់ ជាពិសេស ស្របតាមលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍យុត្តិធម៌ ។
- បានចូលរួមយ៉ាងសកម្មទាំងកម្មវិធីបណ្តុះបណ្តាល និង កម្មវិធីការងាររបស់សមាគមជាតិក្រុមប្រឹក្សា រាជធានី ខេត្ត ដែលក្នុងនោះមានតួនាទីជាថ្នាក់ដឹកនាំ និងសមាជិករបស់សមាគមជាតិ។
- បានទទួលការបណ្តុះបណ្តាលជាបន្តបន្ទាប់ តាមរយៈវគ្គបណ្តុះបណ្តាលហ្វឹកហ្វឺនផ្ទាល់ ធ្វើឲ្យសមាជិក ក្រុមប្រឹក្សាមានការយល់ដឹងពីតួនាទីរបស់ខ្លួនបានល្អប្រសើរ ។
- បានចូលរួមសកម្មភាពនានា ទាំងសកម្មភាពអភិវឌ្ឍន៍ សកម្មភាពសង្គម និងសកម្មភាពផ្នែកសាសនា
- បានទំនាក់ទំនងល្អប្រសើរ រវាងគណៈអភិបាលខេត្ត និងក្រុមប្រឹក្សាខេត្ត និងប្រាស្រ័យទាក់ទងជាមួយ មន្ទីរ អង្គភាពជំនាញ ក្រុមប្រឹក្សាប្រភេទរួមគ្នា និងក្រុមប្រឹក្សាប្រភេទផ្សេងគ្នាជាមួយក្រុមប្រឹក្សាខេត្ត ក៏ មានភាពល្អប្រសើរ ក្នុងនោះក្រុមប្រឹក្សាបានអញ្ជើញតំណាងមន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធ មកចូល រួមប្រជុំទៀងទាត់ ដើម្បីរាយការណ៍ ។

- **ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស**
  - បានបើកវគ្គបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធ ក្នុងនោះ ឆ្នាំ២០១៩ មាន១៨វគ្គ ចំនួន ១១៥ថ្ងៃ មាន អ្នកចូលរួម ៤ ៩២៨នាក់ ស្ត្រីចំនួន ១ ៧៧៥នាក់ និងឆ្នាំ២០២០ មាន៩វគ្គ ចំនួន ៥៩ថ្ងៃ អ្នកចូល រួម ៤ ៣៩៣នាក់ ស្ត្រីចំនួន ១ ៧៦៥ នាក់
  - បានគាំទ្រថវិកាដល់ការរៀបចំកម្មវិធីអ្នកដឹកនាំវ័យក្មេង ដោយមានការចូលរួមពីមន្ត្រីរាជការថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងមន្ទីរ អង្គភាពមួយចំនួន ចាប់ពីឆ្នាំ២០១៦ រហូតមកដល់ឆ្នាំ២០១៩ សរុប ៣ជំនាន់ មានសិក្ខាកាមសរុបចំនួន ៩០នាក់ ចំណាយថវិកាសរុប ១២០លានរៀលនិង ២៩ ១៥៥ ដុល្លារអាមេរិក ។
  - ប្រកាសសមាហរណកម្មបុគ្គលិកនៅរដ្ឋបាលក្រុង ស្រុក និងតាមការិយាល័យជំនាញទៅក្នុងរចនាស ម្ព័ន្ធថ្មីរដ្ឋបាល ក្រុង ស្រុក ចំនួន ៧២២នាក់ ស្រី១៩៧នាក់។
  - ប្រកាសផ្ទេរបុគ្គលិកសុខាភិបាលចំនួន ១ ៤៣៧នាក់ មកឲ្យរដ្ឋបាលខេត្តជាអ្នកគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ ដើម្បីឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។
- **ការផ្តល់សេវា និងការពង្រឹងគណនេយ្យភាព**
  - បានដាក់ឲ្យដំណើការអង្គភាពច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត ដើម្បីផ្តល់សេវាសាធារណៈជូនប្រជា ពលរដ្ឋចាប់តាំងពីឆ្នាំ២០១៨។ បច្ចុប្បន្ន បាននិងកំពុងផ្តល់សេវា ចំនួន ៧០៥សេវា ស្មើនឹង១៤វិស័យ

- អង្គភាពច្រកចេញចូលតែមួយបានរៀបចំវគ្គបណ្តុះបណ្តាល អំពីកិច្ចដំណើរការរបស់ការិយាល័យច្រកចេញចូលតែមួយ និងការផ្តល់សេវា ព្រមទាំងការប្រើប្រាស់ព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងផ្តល់សេវាក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។
- ចំណូលពីការផ្តល់សេវា ថ្នាក់ខេត្ត ក្នុងឆ្នាំ២០១៨ មានចំនួន ១៤៣ ៣១៨ ០០០រៀល ,ឆ្នាំ២០១៩ មានចំនួន ៤ ១៤៨ ៧០៣ ០០០រៀល និងឆ្នាំ២០២០ មានចំនួន ៦ ៧៥៥ ៦០១ ៧៣០រៀល គឺចំណូលមានការកើនឡើងជារៀងរាល់ឆ្នាំ។
- ការិយាល័យប្រជាពលរដ្ឋខេត្ត បានសម្រុះសម្រួលដោះស្រាយបណ្តឹងបានចំនួន ១៣១ករណី ក្នុងនោះ បានសម្រុះសម្រួលដោះស្រាយបញ្ចប់ ៩៨ករណី កំពុងដំណើរការ ០១ករណី និងបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ច ៣២ករណី ។

**ការងារអន្តរាគមន៍គាំទ្រដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ និងការដោះស្រាយបញ្ហាគ្រោះមហន្តរាយនានាះ**

- **ការដោះស្រាយទំនាស់ដីធ្លី** តាមរយៈយន្តការគណៈកម្មការសុរិយោដីខេត្ត បានទទួលបណ្តឹង ចំនួន ២៥៣ករណី(ដោះស្រាយរួច ៧ករណី បាននិងកំពុងដោះស្រាយក្នុងរដ្ឋបាលខេត្ត ១១១ករណី បង្វែរសមត្ថកិច្ចទៅស្ថាប័នតុលាការ ៧ករណី បង្វែរទៅសមត្ថកិច្ចដោះស្រាយ ១២៨ករណី។
- **ការដោះស្រាយបញ្ហាគ្រោះមហន្តរាយ** តាមរយៈយន្តការគណៈកម្មាធិការគ្រប់គ្រងមហន្តរាយខេត្ត បានអនុវត្តការងារអន្តរាគមន៍ស្តារឡើងវិញ នៅតាមបណ្តាក្រុង ស្រុក រងផលប៉ះពាល់ពីជំនន់ទឹកភ្លៀង ដូចជា ក្រុងតាខ្មៅ ស្រុកកណ្តាលស្ទឹង ស្រុកអង្គស្នួល ស្រុកស្អាង និងស្រុកពញាឮ ។

**ការងារទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ តាមច្រកទ្វារព្រំដែន និងនៅតាមបណ្តាក្រុង ស្រុក**

- ខេត្តបានយកចិត្តទុកដាក់ចំពោះការងារចត្តាឡីស័កតាមច្រកទ្វារអន្តរជាតិ ដោយបានចាត់តាំងឱ្យមានមន្ត្រីសុខាភិបាលប្រចាំការត្រួតពិនិត្យសុខភាព អ្នកដំណើរ នាវិក និយោជិត ឆ្លងដែនតាមច្រកអន្តរជាតិ ជ្រៃធំ និងក្អមសំណ(ជាលទ្ធផលៈ ត្រួតពិនិត្យសុខភាពអ្នកដំណើរចេញចូលបាន ១១ ២៦៥ នាក់, នាវិក និយោជិកបំរើការងារលើនាវា យាន្តដឹកជញ្ជូន ៩៥៦៦ នាក់, ត្រួតពិនិត្យនិងធ្វើបែបបទនាវា សាឡង់ យានដឹកជញ្ជូន ១ ៩២៣គ្រឿង, បាញ់ថ្នាំសម្លាប់មេរោគលើយាន្តដឹកជញ្ជូន ៣៤៥ គ្រឿង,ករណីសង្ស័យកូវីដ-១៩ ត្រូវធ្វើចត្តាឡីស័ត ចំនួន ១៣នាក់ ស្រី ០៤នាក់) ។
- បានអនុវត្តវិធានការណ៍ឆ្លើយតបទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ តាមបណ្តាក្រុង ស្រុក ដោយរៀបចំមណ្ឌលចត្តាឡីស័ក សរុបចំនួន ១៨កន្លែង(មណ្ឌលចត្តាឡីស័កកម្រិត១ ចំនួន ១២កន្លែង និងមណ្ឌលចត្តាឡីស័កកម្រិត២ ចំនួន៦កន្លែង) និងបានរៀបចំក្រុមគ្រូពេទ្យឆ្លើយតបបន្ទាន់ ២៧០នាក់
- បានរៀបចំធ្វើតេស្តរកមេរោគកូវីដ-១៩ ដែលជាលទ្ធផល ចំនួនសំណាកសរុប ៣ ១០៣ករណី។
- បានធ្វើបាញ់ថ្នាំនៅទីតាំងសំខាន់ៗ បានចំនួន ១១៣កន្លែង។
- បានចូលរួមបរិច្ចាគថវិកាជាមួយសម្តេចតេជោនាយករដ្ឋមន្ត្រី ទិញវ៉ាក់សាំងការពារជំងឺកូវីដ១៩ ថវិកាសរុបចំនួន ២២៧ ៩០៣ ៩០០រៀល និង៣៩ ១៦៤ដុល្លារ ។

- **<u>ការងារហិរញ្ញវត្ថុ និងការរៀបចំផែនការអភិវឌ្ឍមូលដ្ឋាន</u>**
  - បានអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ(២០២០-២០២៤) កម្មវិធីវិនិយោគបីឆ្នាំរំកិល និងរាល់គម្រោងរវាងដៃគូអភិវឌ្ឍ គម្រោងផែនការវិនិយោគ និងកម្មវិធីលើការរៀបចំផែនការជារៀងរាល់ឆ្នាំ។

- ឆ្នាំ២០២០ ចំណូលថវិកាប្រចាំឆ្នាំរបស់ខេត្ត អនុវត្តបាន ១៣៣ ៩៤១ ១០៩ ០០០ រៀល (មួយរយសាមសិបបីប៊ីលានប្រាំបួនរយសែសិបមួយលានមួយរយប្រាំបួនពាន់រៀលគត់) ស្មើនឹង ២៣៦,៤០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ អនុម័ត ៥៦ ៦៥៧ ៤០០ ០០០រៀល។
- បានរៀបចំគាំទ្រការអនុវត្តគម្រោងឆ្នាំ២០២០ របស់រដ្ឋបាលខេត្ត ៦២គម្រោង(អនុវត្តចប់៤០ កំពុងអនុវត្ត ២២) គម្រោងរបស់ក្រុង ស្រុក ២៨គម្រោង គម្រោងរបស់ឃុំ សង្កាត់ ១៤០គម្រោង និងការថែទាំ ជួសជុលផ្លូវក្នុងខេត្តជាប្រចាំ ។
- ឆ្នាំ២០១៩ គម្រោងរបស់រដ្ឋបាលខេត្ត ចំនួន ១៣៩គម្រោងត្រូវបញ្ចប់ ១០០ %ក្នុងនោះ វិស័យសេដ្ឋកិច្ច៤១ វិស័យសង្គមកិច្ច១ វិស័យគ្រប់គ្រងដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ៥ វិស័យរដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ១៥គម្រោង
- បានគាំទ្រ លើកទឹកចិត្ត ជំរុញដល់ការកសាង ជួសជុល ថែទាំផ្លូវគមនាគមន៍ជាប្រចាំ
- រដ្ឋបាលខេត្តបានវិភាជន៍ចំនួន ៤,៥% នៃថវិកាគុណប្រយោជន៍ខេត្តប្រចាំឆ្នាំគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ និង៤,៥% នៃថវិកាគុណប្រយោជន៍ខេត្តប្រចាំឆ្នាំគាំទ្រដល់រដ្ឋបាលក្រុង ស្រុក
- គម្រោងសាងសង់ផ្លូវក្រវ៉ាត់ក្រុងទី៣ មានប្រវែងសរុប ៥២,៩៨គ.ម ក្នុងនោះកំណាត់ផ្លូវក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ប្រវែង ១៥,៤២គ.ម និងកំណាត់ផ្លូវក្នុងភូមិសាស្ត្រខេត្តប្រវែង ៣៧,៥៦គ.ម គ្រោងនឹងបញ្ចប់នៅឆ្នាំ២០២២ ហើយបច្ចុប្បន្នសាងសង់បានប្រមាណ ៦៥%។
- គម្រោងសាងសង់ព្រលានយន្តហោះភ្នំពេញថ្មី លើផ្ទៃដីទំហំសរុប ២ ៦០០ហិកតា(ខេត្ត២ ៤២៦,២៧ហិកតា បាននិងកំពុងដំណើរការសាងសង់ទៅតាមការកំណត់ ។
- សម្រាប់ឆ្នាំ២០២១ គ្រោងចំណូលសរុប ៤៧ ១១១លានរៀល ក្នុងនោះ ចំណូលសារពើពន្ធ ៣១ ៥៨៨លានរៀល ចំណូលមិនមែនសារពើពន្ធ ១៥ ៥២៣លានរៀល។
- គម្រោងរបស់រដ្ឋបាលខេត្តក្នុងឆ្នាំ២០២១ សរុប ៤២គម្រោង(២៦ ៣៦៥លានរៀល) ក្រោយវិចារណកម្មនៅសល់ ១៨គម្រោង(៧ ៦៧៧លានរៀល) វិស័យសេដ្ឋកិច្ច ១១គម្រោង វិស័យសង្គមកិច្ច ១គម្រោង វិស័យគ្រប់គ្រងដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ៤គម្រោង វិស័យរដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ២គម្រោង។

- **ការងារព្រំដែន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ**
  - ខេត្តកណ្តាល មានព្រំប្រទល់ជាប់នឹងខេត្តអានយ៉ាង នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម មានខ្សែព្រំដែនប្រវែងប្រមាណ ២៩,៥ គ.ម
  - មានស្រុកចំនួន២ នៅជាប់តាមបណ្តោយខ្សែបន្ទាត់ព្រំដែន គឺ ស្រុកកោះធំ និង ស្រកលើកដែក និងឃុំ ចំនួន៣ គឺឃុំក្អមសំណ(ស្រុកលើកដែក) ឃុំព្រែកជ្រៃ និងឃុំសំពៅពូន(ស្រុកកោះធំ)
  - មានភូមិចំនួន៨ ជាប់ព្រំដែន គឺភូមិក្អមសំណក្រោម ឃុំក្អមសំណ ស្រុកលើកដែក, ភូមិបាក់ណាម ភូមិខ្នាតាំងយូ ភូមិខ្នាតាំងយូត្បូង ភូមិព្រែកទន្លា ភូមិព្រែកជ្រៃក្រៅ ឃុំព្រែកជ្រៃ និងភូមិព្រែកជ្រៃធំ និងភូមិព្រែកស្បូវ ឃុំសំពៅពូន។
  - បានយកចិត្តទុកដាក់ខ្ពស់លើការងារសន្តិសុខ និងការអភិវឌ្ឍនៅតំបន់ព្រំដែន ស្របទៅនឹងគោលបំណងរបស់រាជរដ្ឋាភិបាល " **ប្រែក្លាយតំបន់ព្រំដែនឱ្យទៅជាទីប្រជុំជន** " ដោយបានកសាងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនានា និងកែលម្អសោភ័ណភាព ទាក់ទាញទេសចរណ៍ និងបម្រើឱ្យការអភិវឌ្ឍតាមតំបន់ព្រំដែន(មានគណៈកម្មការអភិវឌ្ឍន៍ព្រំដែនខេត្ត,ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ លើផ្ទៃដីទំហំ ២ ៧០០ហិកតា នៅឃុំសំពៅពូន ស្រុកកោះធំ, បង្កើតច្រកទ្វារសំខាន់ៗ ០៤ គឺច្រកទ្វារត្រួតពិនិ

ត្យព្រំដែនអន្តរជាតិជ្រៃធំ ច្រកទ្វារត្រួតពិនិត្យអន្តរជាតិក្អមសំណ ច្រកទ្វារតំបន់ ព្រែកជ្រៃ-ព្រែកទន្លា និងច្រកទ្វារតំបន់ ព្រែកស្បូវ, សិក្សារួចរាល់គម្រោងសាងសង់អគាររដ្ឋបាលច្រកទ្វារព្រំដែនអន្តរជាតិជ្រៃធំ លើផ្ទៃដី ១១២ ៧០០ម៉ែត្រ² ។

- បានសាងសង់ប្រាំងរឹងមាំការពារត្រង់បង្គោលព្រំដែនលេខ២៤៥/៤(១) ស្ថិតក្នុងភូមិព្រែកជ្រៃ ឃុំព្រែកជ្រៃ ស្រុកកោះធំ សរុបប្រវែង ១ ២៩០ម៉ែត្រ ដើម្បីការពារក្នុងបញ្ចៀស និងកាត់បន្ថយចរន្តទឹកផ្នែកខាងក្រោមបាតទន្លេ និងសាងសង់ប្រាំងការពារ ត្រង់បង្គោលលេខ២៤៦/២(១) ស្ថិតនៅភូមិជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ សរុបប្រវែង ១០០ ម៉ែត្រ ។
- បានសហការយ៉ាងល្អក្នុងការថែរក្សាស្ថេរភាព សន្តិសុខសណ្តាប់ធ្នាប់តាមខ្សែបន្ទាត់ព្រំដែន រួមចំណែកពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការមិត្តភាព រវាងកងកម្លាំងសមត្ថកិច្ចឈរជើងនៅព្រំដែននៃប្រទេសទាំងពីរ ដោយឈរលើគោលការណ៍ គោរពឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដី ពិសេសជាងនេះ ថ្នាក់ដឹកនាំខេត្តទាំងពីរកណ្តាល-អានយ៉ាង តែងតែប្រជុំប្តូរវេណ៦ខែម្តង ដើម្បីពិនិត្យដោះស្រាយបញ្ហាផ្សេងៗ (ឆ្នាំ២០២០ ត្រូវបានផ្អាកជាបណ្តោះអាសន្ន ដោយសារបញ្ហាកូវីដ១៩)។
- បានលុបបំបាត់ច្រករបៀងទាំងស្រុង ហើយការលក់ ឬជួលដីស្រែ ដីចំការ ឬលំនៅឋាននៅតាមព្រំដែនឲ្យទៅប្រជាពលរដ្ឋនៃប្រទេសវៀតណាមក៏ត្រូវបានបញ្ឈប់ទាំងស្រុង រហូតមកដល់បច្ចុប្បន្ន(តាមស្មារតីសារាចរលេខ ០៨ សរ របស់រាជរដ្ឋាភិបាលចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥) ។

**៣.យន្តការជំរុញ និងគាំទ្រប្រសិទ្ធភាពការងាររបស់មូលដ្ឋាន (ឃុំ សង្កាត់)**

- ដើម្បីធានាបាននូវគុណភាព ប្រសិទ្ធិភាព និងបរិយាប័ន្ន ក្នុងការគាំទ្រមូលដ្ឋាន ឃុំ សង្កាត់ បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យលេខ ២១៦អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ និងតាមរយៈយន្តការរបស់គណៈកម្មាធិការជាកាតព្វកិច្ចទាំង០៣ និងគណៈកម្មាធិការចំពោះកិច្ច និងអង្គភាព២ ទីចាត់ការ៥ ពិសេស យន្តការរបស់អង្គភាពច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ។
- បានសហការជាមួយក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក ដើម្បីពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ទូទាំងខេត្ត ក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ។
- គណៈអភិបាលខេត្ត ក្រុង ស្រុក មេឃុំ ចៅសង្កាត់ មានភារកិច្ចអនុវត្តកិច្ចការប្រចាំថ្ងៃក្នុងការទំនាក់ទំនងទៅវិញទៅមករវាងខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងនាមក្រុមប្រឹក្សាខេត្ត ។
- បានគាំទ្រ និងការត្រួតពិនិត្យនីត្យានុកូលភាពលើ សេចក្តីសម្រេច និង សកម្មភាពរបស់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីធានាថា រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាល ឃុំ និងរដ្ឋបាល សង្កាត់ បំពេញមុខងារ និងភារកិច្ចដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្ម ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- បានដាក់ចេញនូវដីកា និងសេចក្តីសម្រេចមួយចំនួន ដើម្បីធានាដល់ការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍនៅមូលដ្ឋាន ។
- បានបំពេញតួនាទីខាងលើនេះ ធានាបានស្វ័យភាពរបស់ក្រុង ស្រុក ឃុំ និងសង្កាត់ ស្របតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តនានា ។

- បានធ្វើប្រតិភូកម្មអំពីការគាំទ្រ និងការត្រួតពិនិត្យនីត្យានុកូលភាពនេះដល់ គណៈអភិបាលខេត្ត ដើម្បីអនុវត្តកិច្ចការប្រចាំថ្ងៃ ។
- បានទទួលប្រតិភូកម្មពីរាជរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រ ការសម្របសម្រួល និងការធ្វើសហប្រតិបត្តិការជាមួយរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីរួមគ្នាសម្រេចឱ្យបាននូវគោលនយោបាយរបស់ជាតិ ។
- គាំទ្រថវិការៀងរាល់ឆ្នាំដល់ គ.ក.ស.កជាបន្តបន្ទាប់ ក្នុងនោះឆ្នាំ២០២០គាំទ្រ ១៣០លានរៀល និងឆ្នាំ២០២១ គាំទ្រ ១១៨លានរៀល និងបានប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្ត គាំទ្រដល់មត្តេយ្យសិក្សាសហគមន៍ទូទាំងខេត្ត គាំទ្រទាំងស្មារតី សម្ភារៈ ថវិកា និងចលនាបំផុសការចូលរួមគាំទ្រ
- ឆ្នាំ២០២០ និងឆ្នាំ២០២១ រដ្ឋបាលខេត្តបានគាំទ្រថវិកាចំនួន ២០០លានរៀល ក្នុងមួយឆ្នាំ ដើម្បីទិញសម្ភារៈសិក្សា ផ្គត់ផ្គង់ដល់ដំណើការបង្រៀន និងរៀន និងថវិកា ៥០លានរៀល សម្រាប់ការសាងសង់មត្តេយ្យសហគមន៍ ១កន្លែងបន្ថែមទៀត នៅឃុំទួលព្រេជ ស្រុកអង្គស្នួល ។

**៤. បញ្ហាប្រឈម**

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលធំៗដូចបានគូលបញ្ជាក់ខាងលើ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះៗមួយចំនួនដែលត្រូវបន្តដោះស្រាយដូចខាងក្រោម៖

**ទី១.**បញ្ហាប្រឈមពាក់ព័ន្ធនឹងសមាហរណកម្មរចនាសម្ព័ន្ធថ្មី នៃរដ្ឋបាលក្រុង ស្រុក៖ ការិយាល័យមួយចំនួនក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក មិនទាន់មានមន្ត្រី និងធនធាន សមស្រប ដើម្បីឆ្លើយតបនឹងតម្រូវការការងារជាក់ស្តែងនៅឡើយ ដូចជា ការិយាល័យគ្រប់គ្រងធនធានមនុស្ស ការិយាល័យលេខាធិការក្រុមប្រឹក្សា និងការិយាល័យត្រួតពិនិត្យផ្ទៃក្នុងជាដើម លើសពីនេះ ការយល់ដឹងអំពីរចនាសម្ព័ន្ធរដ្ឋបាលថ្មី និងរបៀបរបបបំពេញការងារ នៅមានកម្រិត ដែលទាមទារឲ្យមានការបណ្តុះបណ្តាលបន្ថែម។

**ទី២.**បញ្ហាប្រឈមពាក់ព័ន្ធនឹងវិមជ្ឈការហិរញ្ញវត្ថុ និងការអភិវឌ្ឍមូលដ្ឋាន៖ កិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលមួយចំនួនត្រូវពន្យាពេលអនុវត្ត និងត្រូវលើកពេលមិនបានអនុវត្តតែម្តង ដោយសារបញ្ហារីករាលដាលនៃជំងឺកូវីដ១៩ ចំណែកមន្ត្រីគាំទ្រក្រុងស្រុកភាគច្រើន ថ្មី មិនទាន់យល់ច្បាស់ពីប្រព័ន្ធគ្រប់គ្រងនិងតាមដាននៅថ្នាក់ក្នុងស្រុក ទន្ទឹមនេះ ការយល់ដឹង និងចំនួនមន្ត្រីរបស់មន្ត្រីស្រុក ក្រុងកន្លងមកនៅមានកម្រិត នាំឲ្យដំណើរការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ មានភាពយឺតយ៉ាវ និងមានការលំបាកក្នុងការអនុវត្តមុខងារជាអាណត្តិទូទៅ(មុខងារជាជម្រើស)បែបសេវាកម្ម ខណៈដែលគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅតែជាអាទិភាព។

**ទី៣.**បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស៖ វគ្គបណ្តុះបណ្តាលមួយចំនួនមិនត្រូវបានរៀបចំ ឬក៏លើកពេល ដោយសារប្រឈមនឹងបញ្ហារីករាលដាលនៃជំងឺកូវីដ១៩ ហេតុនេះ ទាមទារការបណ្តុះបណ្តាលជាច្រើនទៀត ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាប្រកបដោយគុណភាព និងការអនុវត្តមុខងារថ្មីៗ ដែលត្រូវបានផ្ទេរ ឬប្រតិភូកម្មពីថ្នាក់ជាតិ។

**ទី៤.**បញ្ហាប្រឈមពាក់ព័ន្ធនឹងការធ្វើគណនេយ្យភាពចំពោះប្រជាពលរដ្ឋ៖ ការឆ្លើយតបទៅនឹងពាក្យបណ្តឹង និងព័ត៌មានផ្សេងៗរបស់រដ្ឋបាលស្រុក មន្ទីរ អង្គភាពពាក់ព័ន្ធមួយចំនួនមានភាពយឺតយ៉ាវ និងឯកសារមួយចំនួនមានការកកស្ទះមិនបានអនុវត្តទៅតាមការកំណត់។ ម្យ៉ាងទៀត ទោះបីជាមានយន្តការជាច្រើនដើម្បីធានាការចូលរួមមតិយោបល់ និងតាមដានការបំពេញការងាររបស់រដ្ឋបាលខេត្ត ក៏ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានមួយចំនួននៅមានកម្រិតនៅឡើយ។

**ទី៥.**បញ្ហាប្រឈមពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាៈ ការបំពេញការងារភាគច្រើននៅប្រជាសស្នាម និងធ្វើការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋដោយផ្ទាល់ ម្យ៉ាងទៀតកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលនៅមិនទាន់បានអភិវឌ្ឍឱ្យបានពេញលេញ និងតភ្ជាប់ជាមួយនឹងកម្មវិធីផ្តល់សេវារបស់ក្រសួង ស្ថាប័នផ្សេងៗ។

**៥. ទិសដៅការងាររបស់ក្រុមប្រឹក្សាខេត្ត**

ជាមួយនឹងសមិទ្ធផលការងារសំខាន់ៗជាច្រើន រដ្ឋបាលខេត្តនឹងខិតខំយកចិត្តទុកដាក់បន្ថែមទៀតលើកិច្ចការចាំបាច់មួយចំនួនឆ្លើយតបនឹងបញ្ហាប្រឈមខាងលើ និងការងារអាទិភាពដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដើម្បីធានាការអនុវត្តតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងកម្មវិធីជាតិដំណាក់កាលទី២ របស់ គ.ជ.អ.ប ដែលរដ្ឋបាលខេត្តនឹងផ្តោតលើការងារអាទិភាពនានា ដូចខាងក្រោមៈ

**ទី១.**បន្តពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង និងមុខងាររបស់រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុកៈ រដ្ឋបាលខេត្តនឹងសហការគាំទ្រ និងផ្តល់ការបណ្តុះបណ្តាលបន្ថែមទៀត ដល់មន្ត្រីក្នុងរចនាសម្ព័ន្ធចំណុះរដ្ឋបាលក្រុង ស្រុក ដើម្បីធានាបានការអនុវត្តតួនាទី ភារកិច្ច និងប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព ជាពិសេសការអនុវត្តមុខងារ ដែលបានផ្ទេរ និងប្រតិភូកម្ម មកក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ទន្ទឹមនេះ រដ្ឋបាលខេត្តនឹងពិនិត្យឡើងវិញនូវមុខងារសំខាន់ៗមួយចំនួន ពាក់ព័ន្ធភាពជាតំណាងរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងមុខងារគាំទ្រដល់ការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន ដើម្បីប្រែក្លាយជារដ្ឋបាលតំបន់ តាមគោលការណ៍រដ្ឋបាលឯកភាព។

**ទី២.**ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សៈ បន្តជំរុញ និងគាំទ្រយន្តការមណ្ឌលអភិវឌ្ឍធនធានមនុស្ស ដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីរាជការក្នុងរដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ និងបន្តពង្រឹងសមត្ថភាពគ្រប់គ្រង ចាត់ចែង ជាពិសេសការទទួលខុសត្រូវពេញលេញក្នុងការជ្រើសរើសបុគ្គលិក ផ្អែកតាមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

**ទី៣.**ការផ្តល់សេវាសាធារណៈ និងអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិកៈ បន្តផ្តល់ការអភិវឌ្ឍសមត្ថភាពព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយឱ្យបានកាន់តែប្រសើរ ដើម្បីឈានដល់ការផ្តល់សេវាតាមប្រព័ន្ធអនឡាញ ព្រមទាំងជំរុញការអនុវត្តប្រព័ន្ធអេឡិចត្រូនិកក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលខេត្តជាបណ្តើរៗ លើកិច្ចការសំខាន់ៗ ដូចជា ទំនាក់ទំនងការងាររវាងរដ្ឋបាល និងរដ្ឋបាល ទំនាក់ទំនងការងាររវាងរដ្ឋបាល និងប្រជាពលរដ្ឋ ការផ្សព្វផ្សាយព័ត៌មាន និងការអភិវឌ្ឍសមត្ថភាព។

**ទី៤.**កិច្ចការអន្តរវិស័យៈ បន្តផ្តោតលើការលើកកម្ពស់ការងារចាំបាច់នានា រួមមាន ការងារយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ តាមរយៈការបញ្ជ្រាបកិច្ចការទាំងនេះមកក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខេត្ត ដើម្បីធានាលទ្ធភាពពេញលេញក្នុងការគ្រប់គ្រងធនធានមនុស្ស ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយគ្មានការរើសអើង និងឆ្លើយតបនឹងបញ្ហានានាដែលបានកើតមាន បានទាន់ពេលវេលា។

ជាទីបញ្ចប់ក្នុងនាមរដ្ឋបាលខេត្តកណ្តាល ខ្ញុំបាទសូមគោរពជូនពរ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល គណៈប្រតិភូខេត្តកណ្តាល និងឯកឧត្តម លោកជំទាវ និងបងប្អូនអ្នកសារព័ត៌មានដែលមានវត្តមាននាឱកាសនេះ សូមជួបប្រទះនូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕